# ប្រវត្តិសង្ខេបរបស់គណបក្សកុម្មុយនីស្តខ្មែរ

**១/៧៥**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Apr-2011, 08:41
CMS/CFO: Ly Bunloung

ប្រវត្តិសង្ខេបរៀតណាមតាមឯកសារមីក្រូហ្វីម

ការបកប្រែថ្មីៗអំពីឯកសារកុម្មុយនីស្តខ្មែរដែលប្រមូលបាន បានផ្តល់សេចក្តីលម្អិតដ៏កម្រមួយចំនួនស្តីពីប្រវត្តិសាស្ត្រដើមរបស់គណបក្សកុម្មុយនីស្តកម្ពុជា ។ ឯកសារនេះ ត្រូវបានបោះពុម្ពដោយអង្គភាពនយោបាយ/យោធារបស់ការិយាល័យមជ្ឈិម ប្រចាំភូមិភាគបូព៌ារបស់គណបក្សកុម្មុយនីស្តកម្ពុជា ពោលគឺប្រហែលជាក្នុងពេលរៀបចំប្រារព្ធខួបលើកទី ២២ របស់គណបក្សនៅខែកញ្ញា ឆ្នាំ ១៩៧៣ និងនិយាយអំពីប្រវត្តិបក្ស ការដោះស្រាយបញ្ហា និងគោលបំណងរបស់គណបក្សពីឆ្នាំ ១៩៥១ ដល់ឆ្នាំ ១៩៦៧ ។ ឯកសារនេះយកចិត្តទុកដាក់ពិសេសលើប្រធានបទទាំងឡាយ និងការនិយាយពីស្វ័យទិទៀនជាញឹកញាប់ បង្ហាញថាឯកសារនេះត្រូវបានផ្សព្វផ្សាយសំរាប់ប្រើប្រាស់ផ្ទៃក្នុងគណបក្ស ក្នុងចំណោមសមាជិកថ្នាក់ខ្ពស់ ។ កំណត់ពន្យល់មួយស្ថិតនៅជិតចុងឯកសារ លើកឡើងថា “បទបង្ហាញសង្ខេបនៃប្រវត្តិគណបក្ស គឺជាឯកសារលើកដំបូង ដែលមានចំណុចខ្វះខាតជាច្រើន” ។ ទោះបីជាមានចំណុចខ្វះខាត និងអាចមានសេចក្តីមិនពិតខ្លះក្តី ក៏ឯកសារនេះបញ្ជាក់ពីទិដ្ឋភាពជាច្រើននៃប្រវត្តិដើមរបស់គណបក្ស ដែលរហូតមកដល់ពេលនេះគ្រាន់តែជាការសន្និដ្ឋានរបស់របស់បញ្ញវន្ត ។

យោងតាមឯកសារនេះ គណបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្កើតឡើងនៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៥១ “ដោយមានការគាំទ្រយ៉ាងរឹងមាំពីគណបក្សពលករវៀតណាមខាងជើង (ឡាវដុង)” ដែលបានប្តូរឈ្មោះមកពីបក្សកុម្មុយនីស្តឥណ្ឌូចិននាពេលថ្មីៗនេះ ។ ទោះជាឯកសារនេះ មិនបានលើកឡើងអំពីគណបក្សនេះក្តី ក៏ក្រុមរណសិរ្សមួយមានឈ្មោះថា គណបក្សបដិវត្តន៍ប្រជាជនកម្ពុជា ត្រូវបានបង្កើតឡើងប្រហែលស្របពេលដែល ហូ ជីមិញ បានរំលាយបក្សកុម្មុយនីស្តឥណ្ឌូចិនកាលពីខែកុម្ភៈ ឆ្នាំ ១៩៥១ ។ រណសិរ្សថ្មីនេះ ត្រូវបានគិតថាជាអង្គការចាត់តាំងនយោបាយឯករាជ្យមួយសំរាប់សមាជិកវៀតមិញកម្ពុជា ។ សន្និសីទឆ្នាំ ១៩៥១ ដែលបានពិពណ៌នាក្នុងឯកសារនេះ អាចជាកិច្ចប្រជុំរបស់គណបក្សបដិវត្តន៍កម្ពុជា ។ ក្នុងករណីណាក្តី ក៏ឯកសារដែលប្រមូលបាននេះបញ្ជាក់យ៉ាងច្បាស់ថា ខែកញ្ញា ឆ្នាំ ១៩៥១ គឺជាកាលបរិច្ឆេទកំណត់ការបង្កើតគណបក្សកុម្មុយនីស្តកម្ពុជា និងថាសន្និសីទដែលបានប្រារព្ធឡើងនៅពេលនោះ គឺជាការជួបប្រជុំតូចមួយរបស់អតីតសមាជិកគណបក្សឥណ្ឌូចិនកម្ពុជា ដែលសមាជិកទាំងនោះមានការយល់

ដឹងមិនច្បាស់អំពីអត្ថន័យនៃគណបក្ស និងទិសដៅ[1] របស់គណបក្សទេ ។ ទោះជាយ៉ាណាក្តី កិច្ចប្រជុំនេះ ពិតជាបានបង្កើត "គណៈកម្មការផ្សព្វផ្សាយនិងបង្កើត" ដែលមានសមាជិក ៤រូប និងមានភារកិច្ចរៀបចំគណបក្សកុម្មុយនីស្តសម័យដើម តាមគំរូរបស់វៀតណាម និងសូវៀត ។

សមាជិកគណៈកម្មាការនេះ ត្រូវបានបង្ហាញតែតាមរយៈអក្សរដំបូងនៃឈ្មោះរបស់អ្នកទាំងនោះប៉ុណ្ណោះ ប៉ុន្តែសមាជិកគណៈកម្មការទាំងនោះ អាចជាលោក សឺន ង៉ុកមិញ [Son Ngoc Minh] ស៊ីវ ហេង [Sieu Heng] ទូ សាមុត [Tou Samouth] និងលោក ចាន់ សាម៉័យ [Chan Samay] ។ យើងអាចបានកំណត់ច្បាស់តែលោក ស៊ីវ អេង និងលោក ទូ សាមុត នោះទេ ថាជាសមាជិកគណៈកម្មាការនេះ ។ ថ្នាក់ដឹកនាំដំបូងទាំងបួននេះ បានខិតខំប្រឹងប្រែងអនុវត្តការងារក្នុងអំឡុងពេលស្ថិតក្នុងអណត្តិ[2]របស់ខ្លួន ប៉ុន្តែឯកសារនេះបង្ហាញថាថ្នាក់ដឹកនាំទាំងនេះ ត្រូវបានរាំងដោយសារតម្រូវការនៃ "ការតស៊ូប្រដាប់អាវុធ" ប្រឆាំងនឹងអាណានិកគមនិយមបារាំង ដែលបានបន្តរហូតដល់ពេលមានសន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ ។ គេបានបង្កើតសមិទ្ធផលមួយចំនួនក្នុងវិស័យ "មនោគមវិជ្ជា និងនយោបាយ" ប៉ុន្តែឯកសារនេះបង្ហាញថា "គណបក្សកុម្មុយនីស្តនេះ" គឺ "ដូចជាស្រមោលមួយ" ក្នុងរយៈពេលបីឆ្នាំបន្ទាប់ពីសន្និសីទឆ្នាំ ១៩៥១ ។

---

[1] ឯកសារនេះ បញ្ជាក់ពីសមាជិកជនជាតិខ្មែរមួយក្រុមរបស់គណបក្សកុម្មុយនីស្តបារាំង ដែលមានគ្នា ១០រូប និងសមាជិក ៣ ឬ៤រូប របស់គណបក្សកុម្មុយនីស្តថៃ ដែលមានសកម្មភាពក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលសន្និសីទនៅខែកញ្ញា ឆ្នាំ ១៩៥១ ។ សមាជិកទាំងនេះ ធ្វើការងារដោយឯករាជ្យពីជនរួមជាតិផ្សេងទៀត ដែលទទួលបានការបណ្តុះបណ្តាលពីវៀតណាមរហូតដល់ឆ្នាំ ១៩៥២ ឬ ១៩៥៣ ។

[2] ឧទាហរណ៍: សាររបស់វៀតមិញដែលថតបានបង្ហាញថា លក្ខន្តិកៈរបស់គណបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានព្រាងជាភាសាវៀតណាម នៅការិយាល័យកណ្តាលរបស់វៀតមិញនៅភាគខាងជើងក្នុងឆ្នាំ ១៩៥១ និងត្រូវបានបញ្ជូនទៅកាន់ការិយាល័យកណ្តាលវៀតណាមនៅភាគខាងត្បូង ដើម្បីបកប្រែជាភាសាខ្មែរ ។ ទោះបីជាគេដឹងថា លោក សឺន ង៉ុកមិញ ចេញចូលការិយាល័យវៀតមិញនៅភាគខាងត្បូងជាញឹកញាប់ក្តី ក៏ឯកសារដែលប្រមូលបាននេះបញ្ជាក់ថា មិនមានលក្ខន្តិកៈផ្លូវការ ត្រូវបានអនុម័តនោះទេ រហូតដល់ឆ្នាំ ១៩៦០ មិនមានលក្ខន្តិកៈផ្លូវការ ត្រូវបានអនុម័តនោះទេ រហូតដល់ឆ្នាំ ១៩៦០ ។



រូបថតមេដឹកនាំគណៈបក្សកសាងជាតិ ឆ្នាំ ១៩៤៩ ។ វិលតាមទ្រនិចនាឡិកាពីរូបខ្ពស់បំផុត៖ សឺន ង៉ុក មិញ, ទូ សាមុត, ស៊ីវ ហេង, ចាន់ សាម៉ៃ

"គណបក្ស" បានចាប់ផ្តើមអនុវត្តការិយាធិបតេយ្យមួយចំនួន តាមរយៈការបង្កើតគណៈកម្មការមជ្ឈិមបណ្តោះអាសន្ន ដែលមានសមាជិក ៥រូប ដឹកនាំដោយលោក ស៊ីវ ហេង បន្ទាប់ពីការបញ្ចប់សន្និសីទទីក្រុងហ្សឺណែវ ។ លោក ស៊ីវ ហេង មានភារកិច្ចទទួលខុសត្រូវលើសកម្មភាពនយោបាយប្រឆាំងនឹងសម្តេច សីហនុ តាមរយៈសារព័ត៌មានប្រកាន់ឆ្វេងនិយម និងគណបក្សប្រជាជន ចំណែកឯលោក ទូ សាមុត ដឹកនាំ "គណៈកម្មការទីក្រុង" ។ លោក ស៊ីវ ហេង ផ្ទាល់ទទួលបន្ទុក "គណៈកម្មការជនបទ" ដែលទំនងជាមានភារកិច្ចធ្វើឲ្យទស្សនៈរបស់ប្រជាជនផ្លាស់ប្តូរ និងជ្រើសរើសសមាជិកនៅទីជនបទ ។ ទោះបីយ៉ាងណាក្តី ឯកសារនេះបានកោតសរសើរសកម្មភាពប្រឆាំងរបស់លោក ទូ សាមុត និងកោតសរសើរ "សមាជិកគណបក្សមួយភាគតូច" តែបានពិពណ៌នាថាលោក ស៊ីវ ហេង បានក្លាយខ្លួនជាជនរងគ្រោះដោយសារ "និន្នាការប្រឆាំងបដិវត្តន៍" និង "សេរីនិយម" ។ លោកត្រូវបានស្តីបន្ទោស ដោយសារការធ្វើឲ្យមាន "ការបាត់បង់កម្មាភិបាល និងសមាជិកគណបក្សប្រហែល ៩០ភាគរយ" ហើយការចុះចូលរបស់លោកជាមួយសម្តេច សីហនុ នៅឆ្នាំ ១៩៥៩ ត្រូវបានពិពណ៌នាថាបាននាំឲ្យ "គណបក្ស" ចុះខ្សោយ ។ ឯកសារនេះមិនបានលើកឡើងពីការចុះចូលរបស់លោក ស៊ីវ ហេង ដែលធ្វើឲ្យគណបក្សចុះខ្សោយ

នោះទេ ប៉ុន្តែបានលើកឡើងថា ការប្រមូលផ្តុំកម្មាភិបាលចំនួនដ៏ច្រើនឡើងវិញឆ្ពោះទៅកាន់ប្រទេសវៀតណាមខាងត្បូងក្នុងអំឡុងពេលនេះ ក៏បានធ្វើឲ្យមានការថយចុះកម្លាំងរបស់គណបក្សនេះផងដែរ ។

លោក ទូ សាមុត ជាប្រធាន "គណៈកម្មាការកិច្ចការទូទៅ" បានចាប់ផ្តើមកសាងគណបក្សឡើងវិញនៅចុងឆ្នាំ ១៩៥៩ ។ ទោះបីជាមានការបង្ក្រាបពីសម្តេច សីហនុ លើសកម្មភាពរបស់ពួកឆ្វេងនិយមក្តី ក៏ "មហាសន្និបាតគណបក្សលើកទីពីរ" ត្រូវបានប្រារព្ធឡើងកាលពីថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៦០ ។ មហាសន្និបាតនេះ គឺជាកិច្ចប្រជុំដែលបានអនុម័តលក្ខន្តិកៈ ដែលជាឯកសារនេះផ្ទាល់ បានដាក់ឈ្មោះលក្ខន្តិកៈនេះថា "អ្នកម៉ាក្ស-ឡេនីននិយម" និងបានបង្កើតគណៈកម្មការមជ្ឈិមបក្ស ដែលមានសមាជិក ៨រូប ដោយមានលោក ទូ សាមុត ជាលេខា ។ តាមលក្ខណៈបច្ចេកទេស យ៉ាងហោចណាស់ សកម្មភាពទាំងនេះទំនងជាបង្ហាញពីការបង្កើតបក្សកុម្មុយនីស្តកម្ពុជាលើកដំបូងដ៏ពិតប្រាកដផងដែរ ។

មហាសន្និបាតនៅឆ្នាំ ១៩៦០ នេះ បានបង្ហាញពីការចាប់ផ្តើមកិច្ចប្រឹងប្រែងដ៏ខ្លាំង ដើម្បីកសាងបណ្តាញគណបក្សនៅទូទាំងប្រទេស នឹងដើម្បីបង្កើនសមាជិកភាពរបស់គណបក្ស ។ នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៦២ "សត្រូវបានចាប់ជំរិតលោក ទូ សាមុត ដោយគ្មានបន្សល់ស្លាកស្នាម"[3] ប៉ុន្តែបុគ្គលមិនស្គាល់អត្តសញ្ញាណផ្សេងទៀតបានឡើងកាន់តំណែងជាប្រធានជំនួស និង

---

[3] មានអាថ៌កំបាំងជាខ្លាំងជុំវិញជោគវាសនារបស់លោក ទូ សាមុត ។ អ្នករត់ចោលគណបក្ស ដែលដឹងឮពីបញ្ហានេះ បានអះអាងថា លោក ទូ សាមុត បានបម្រើការងារក្នុងសារព័ត៌មានគណបក្សប្រជាជន បន្ទាប់ពីសន្និសីទក្រុងហ្សឺណែវ និងថា លោកត្រូវបានសម្តេច សីហនុ កម្ទេចចោល "ក្នុងពេលណាមួយក្រោយឆ្នាំ ១៩៥៥" ។ នៅពេលមានការសួរបញ្ជាក់អំពីរឿងនេះកាលពីឆ្នាំ ១៩៧២ លោក ស៊ីវ ហេង បានឆ្លើយតបទាំងគួរឲ្យសង្ស័យថា "លោក លន់ នល់ ជាអ្នកដឹងពីអ្វីដែលបានកើតឡើង" ។ ក្នុងរបាយការណ៍ស្តីពី "ខ្មែរក្រហម" ដែលបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅឆ្នាំ ១៩៧០ លោក លន់ នល់ ដែលកាលនោះនៅជាមេបញ្ជាការកងទ័ពស្ថិតក្រោមការដឹកនាំរបស់សម្តេច សីហនុ បានអះអាងថា លោក ទូ សាមុត នៅតែជា "ប្រធាន" គណបក្សកុម្មុយនីស្តខ្មែរ និងជាមេបញ្ជាកងទ័ពក្នុងតំបន់ឦសាន្តនៃប្រទេសកម្ពុជា ។

នៅឆ្នាំ ១៩៦៣ នៅពេល "មហាសន្និបាត" លើកទីបី ត្រូវបានប្រារព្ធឡើង មានការរបាយការណ៍ថា បក្សមានគោលជំហរបដិវត្តន៍រឹងមាំ ។

ខ្លឹមសារផ្សេងទៀតក្នុងឯកសារនេះ រៀបរាប់ពីការបង្កើតអង្គការបក្ស "ដែលឯកភាព" និង "ត្រឹមត្រូវ" ដែលមានផ្អែកលើ "លទ្ធិម៉ាក្ស-ឡេនីននិយម" ។ ទោះជាយ៉ាងណាក្តី ផ្នែកភាគច្រើននៃឯកសារនេះបានឲ្យដឹងថា ក្នុងរយៈពេលពីឆ្នាំ ១៩៦៣ ដល់ ១៩៦៧ គឺជាពេលវេលាដែលត្រូវដោះស្រាយគោលការណ៍ទូទៅដ៏ទូលំទូលាយ ហើយបាននិយាយលម្អិតជាក់លាក់អំពីប្រវត្តិបក្សតិចតួចណាស់ ។

ទោះជាយ៉ាងណាក្តី ទិដ្ឋភាពដ៏គួរឲ្យចាប់អារម្មណ៍មួយនៃប្រវត្តិរបស់គណបក្ស គឺជាការគ្មានឯកសារបញ្ជាក់អំពីការពាក់ព័ន្ធរបស់គណបក្សក្នុងរដ្ឋបាលរបស់សម្តេច សីហនុ ។ ក្នុងចុងទសវត្សរ៍ឆ្នាំ ១៩៥០ និងដើមទសវត្សរ៍ឆ្នាំ ១៩៦០ សម្តេច សីហនុ បានដាក់យុវជន និងបញ្ញវន្តឆ្វេងនិយមដែលមានសមត្ថភាពមួយក្រុម ក្នុងតួនាទីរដ្ឋាភិបាលជាន់ខ្ពស់ក្នុងគោលបំណងទប់ស្កាត់ការរិះគន់របស់អ្នកទាំងនោះចំពោះរដ្ឋបាលរបស់លោក និងដើម្បីឲ្យពួកគេដោះស្រាយបញ្ហារបស់ជាតិ ។ ក្រុមយុវជន និងបញ្ញវន្ត រួមមានមេដឹកនាំគណបក្សកុម្មុយនីស្តបច្ចុប្បន្ន លោក ខៀវ សំផន [Khieu Samphan] ហ៊ូ យន់ [Hou Youn] និង ហ៊ូ នឹម [Hu Nim] ។ ការមិនបានលើកឡើងអំពីការចូលរួមរបស់រដ្ឋាភិបាលបង្ហាញថា អាចមានប្រភពដ៏គួរឲ្យទុកចិត្តមួយចំនួន ដែលអះអាងថា "បញ្ញវន្តទាំងបីនាក់នេះ" មិនបានចូលរួមក្នុងចលនាបក្សកុម្មុយនីស្តកម្ពុជានោះទេ រហូតទាល់តែសម្តេច សីហនុ ទាត់ចោលពួកគេឲ្យរត់ចូលព្រៃក្នុងឆ្នាំ ១៩៦៧ ។

យោងតាមប្រវត្តិផ្ទាល់របស់លោក លោក ស៊ីវ ហេង គឺជាប្រធានក្រុមតូចមួយរបស់វៀតមិញ ពោលគឺមានទំនាក់ទំនងនឹងពួកទ័ពព្រៃ ដែលប្រយុទ្ធប្រឆាំងនឹងពួកបារាំងក្នុងខេត្តបាត់ដំបង កាលពីឆ្នាំ ១៩៤៧ នៅពេលរូបលោក ត្រូវបានជ្រើសរើសឲ្យធ្វើជាតំណាងរបស់ប្រទេសកម្ពុជាក្នុងសន្និសីទដ៏ធំមួយរបស់គណបក្សកុម្មុយនីស្តឥណ្ឌូចិន ។ នៅទីបំផុត លោកបានចូលរួមជាមួយគណបក្សកសាងជាតិកម្ពុជា ដែលជាគណបក្សធំជាងគេ ហើយក្នុងឆ្នាំ ១៩៤៩ លោកបានក្លាយជាមេដឹកនាំគណបក្សស្របគ្នាជាមួយនឹងលោក សឺន ង៉ុកមិញ, ទូ សាមុត និង ចាន់ សាម័យ

។ លោក ត្រូវបានបញ្ជូនទៅកាន់វៀតណាមខាងជើង បន្ទាប់ពីសន្និសីទក្រុងហ្សឺណែវក្នុងឆ្នាំ ១៩៥៤ និងបានត្រឡប់មកកម្ពុជាវិញក្នុងរយៈពេលមួយឆ្នាំ ដើម្បីជួយដឹកនាំសកម្មភាពប្រឆាំង ។ ក្នុងឆ្នាំ ១៩៥៩ លោកបានក្បត់គណបក្ស និងបានចុះចូលជាមួយសម្តេច សីហនុ ។ ដោយមានការលើកលែងទោស លោកបានចំណាយពេលរយៈពេល ១០ឆ្នាំធ្វើស្រែចំការក្នុងខេត្តបាត់ដំបង ។ បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ក្នុងឆ្នាំ ១៩៧០ លោក លន់ នល់ បានតែងតាំងលោក ស៊ីវ ហេង ក្នុងឋានៈជាវរៈសេនីយ៍ត្រី និងបញ្ជាការកងវរៈសេនាតូចទ័ពថ្មើរជើង រហូតដល់រូបលោកមានជម្ងឺដាច់សរសៃឈាមក្នុងខួរក្បាលក្នុងឆ្នាំ ១៩៧១ ។ មន្ត្រីស្ថានទូតអាមេរិកបានសម្ភាសលោក ស៊ីវ ហេង នៅផ្ទះរបស់លោកក្នុងខេត្តបាត់ដំបងកាលពីដើមឆ្នាំ ១៩៧២ ។ រូបថតដែលលោក ស៊ីវ ហេង ផ្តល់ឲ្យក្នុងបទសម្ភាសឯករាជ្យជាមួយក្រុមអ្នករត់ចេញពីគណបក្សកុម្មុយនីស្តដែលដឹងឮពីប្រវត្តិរបស់លោក ស៊ីវ ហេង និងការផ្សព្វផ្សាយឃោសនារបស់វៀតមិញ សុទ្ធតែអាចបញ្ជាក់ពីប្រវត្តិរបស់លោក ស៊ីវ ហេង បាន ។